# ព្រះគម្ពីរសំរាប់កុមារ
## សូមបង្ហាញជូន

# ព្រះ
# រាជកំណើតនៃព្រះ
# យេស៊ូ




និពន្ធដោយ៖ Edward Hughes
បកប្រែដោយ៖ www.christian-translation.com
ធ្វើការពន្យល់ដោយ៖ M. Maillot
Alastair Paterson
កែសម្រួលដោយ៖ E. Frischbutter; Sarah S.


រឿងទី ៣៦ នៃ ៦០


**www.M1914.org**

***Bible for Children,*** *PO Box 3, Winnipeg, MB R3C 2G1 Canada*



អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។


ភាសាខ្មែរ Khmer








បន្ទាប់មក ទេវតាក៏បានប្រាប់ទៅម៉ារីផងដែរ
ថា អេលីហ្សាប៊ែត ដែលជាបងប្អូនជីដូនមួយ
របស់នាងក៏កំពុងមានផ្ទៃពោះក្នុងវ័យចំណាស់
របស់នាងផងដែរ។ នេះ
ក៏ជាអព្ភូតហេតុដ៏អស្ចា
រ្យមួយដែរ។ មិនយូរ
ប៉ុន្មាន ម៉ារីបានទៅ
លេង អេលីហ្សាប៊ែត។
ពួកគេបានបួងសួង
លើកតម្កើងព្រះ
ជាម្ចាស់ជាមួយគ្នា។
3


ម៉ារីបានភ្ជាប់
ពាក្យទៅបុរស
ម្នាក់ឈ្មោះ ហូស្សេ
ប។ ហូស្សេប មិន
សប្បាយចិត្តទេ
ពេលដែលគាត់
បានដឹងថាម៉ារី
កំពុងមានកូន។
គាត់បានគិតថា
ប្រហែលជាឪពុក
របស់កូននេះជា
បុរសផ្សេងណា
ម្នាក់ហើយ។
4


នៅក្នុងការយល់សប្តិ, ទេវតារបស់
ព្រះបានប្រាប់ហូស្សេបថា កូននេះ
ជាបុត្ររបស់ព្រះ។ ហូស្សេបត្រូវជួយ
ម៉ារីថែទាំព្រះយេស៊ូ។
5


ហូស្សេបជឿជាក់ និងគោរពតាមព្រះជាម្ចាស់។ គាត់ក៏ជា
អ្នកគោរពតាមច្បាស់របស់ប្រទេសគាត់ផងដែរ។ ដោយសារ
តែច្បាប់ថ្មី គាត់និងម៉ារីបាន
ចាកចេញទៅភូមិកំណើត
របស់ពួកគាត់
ឈ្មោះ
បិតឡេហែម ដើម្បីបង់ពន្ធរបស់ពួកគាត់។
6


ម៉ារីដល់ពេលសំរាលកូន
របស់នាងហើយ។ ប៉ុន្តែហូ
ស្សេបមិនអាចរកបាន
បន្ទប់ស្នាក់នៅទីណាសោះ។
គ្រប់ផ្ទះសំណាក់
សុទ្ធតែពេញ។
7


នៅទីបំផុត ហូស្សេបបានរកបានក្រោលសត្វមួយ។ ទីនោះ
ហើយ ដែលជាកន្លែងព្រះឱរសយេស៊ូបានចាប់កំណើត។
មាតាទ្រង់បានដាក់ទ្រង់នៅក្នុង
ស្នូកសត្វមួយដែលជាធម្មតាគឺជា
កន្លែងសម្រាប់
ដាក់ចំណី
សត្វ។
8


នៅមិនឆ្ងាយពីទីនោះ មានពួកអ្នកគង្វាលដែលនៅចាំយាម
រក្សាហ្វូងចៀមរបស់ពួកគេ។ ទេវតារបស់ព្រះជាម្ចាស់បាន
លេចឡើង ហើយប្រាប់ពួកគេពីព័ត៌មាន
ដ៏អស្ចារ្យ
នេះ។
9
“នៅថ្ងៃនេះ មានព្រះសង្គ្រោះមួយអង្គបានប្រសូតដល់អ្នក
រាល់គ្នានៅទីក្រុង ដេវីដគឺជាព្រះគ្រិស្ត ជាព្រះអ
ស្ចារ្យ។ អ្នកនឹងឃើញព្រះឱរសកំពុងផ្ដេក
នៅក្នុងស្នូក
សត្វមួយ។”
10
រំពេចនោះ ទេវតាជាច្រើនបន្ថែមទៀតបានលេចឡើងចែង
ចាំង បានពោលសរសើរតម្កើងព្រះជាម្ចាស់
ដោយពាក្យថា “សូមថ្វាយសិរីល្អដល់ព្រះ
នៅស្ថានដ៏ខ្ពស់បំផុត ហើយ
សូមអោយសុខសន្តិ
ភាពមាននៅលើផែន
ដីដែលជាទីគាប់ព្រះ
រាជហឫទ័យរបស់ទ្រង់។”
11
ពួកអ្នកគង្វាលបានប្រញាប់ទៅក្រោល
សត្វ។ ក្រោយពីបានឃើញព្រះឱរសហើយ ពួក
គេបានប្រាប់ទៅគ្រប់គ្នាដែលពួកគេបានជួប
ពីអ្វីដែលទេវតាបាននិយាយអំពីព្រះយេស៊ូ។
12
៤០ថ្ងៃក្រោយមក ហូស្សែ
ប និងម៉ារីបាននាំព្រះ
យេស៊ូទៅវិហារនៅ ជេរូសា
ឡិម។ មានបុរសម្នាក់
ឈ្មោះ សាយមិន បាន
លើកតម្កើងសរសើរដល់
ព្រះជាម្ចាស់សំរាប់ព្រះ
ឱរស ចំណែក អាណា
ដែលជាស្ត្រីវ័យចំណាស់
ម្នាក់ និងជាអ្នកបម្រើ
ដល់ព្រះផងនោះក៏បាន
អរព្រះគុណដល់ព្រះដែល
បានប្រទានព្រះបុត្រា
ទ្រង់មកស្ថាន
មនុស្សដែរ។
13
អ្នកទាំងពីរសុទ្ធតែដឹងថា
ព្រះយេស៊ូជាបុត្រារបស់
ព្រះ គឺជាព្រះសង្គ្រោះ
ដែលបានសន្យាថានឹង
ត្រូវយាងមក។ ហូស្សែប
បានថ្វាយសត្វស្លាប
ចំនួនពីរដល់ព្រះជាម្ចា
ស់។ នេះគឺជាដង្វាយដែល
ក្នុងក្រឹត្យវិន័យរបស់ព្រះ
បានតម្រូវសំរាប់អ្នកក្រី
ក្រដែលត្រូវថ្វាយចំពោះ
ព្រះ នៅពេលដែលពួកគេ
យកកូនទើបនឹងកើត
បង្ហាញវត្តមាន
ដល់ព្រះជាម្ចាស់។
14


មួយរយះពេលក្រោយ
មក មានផ្កាយពិសេស
មួយបាននាំពួកអ្នក
ប្រាជ្ញមកពីប៉ែកខាង
កើតប្រទេសទៅ
ជេរ៉ូសាឡិម។
“ពួកលោកបានសួរថា តើបុត្រា
ដែលត្រូវប្រសូតមកធ្វើជាស្ដេច
របស់សាសន៍ជ្វីហ្វនៅទីណា?
ពួកយើងខ្ញុំចង់ថ្វាយបង្គំទ្រង់។”
15
ស្ដេចហេរ៉ូត បានលឺពីពួក
អ្នកប្រាជ្ញទាំងនោះ។ ដោយ
មានព្រះទ័យតក់ស្លុត ទ្រង់ក៏
បានសុំអោយពួកអ្នកប្រាជ្ញ
ទាំងនោះប្រាប់ដល់ទ្រង់វិញ
ផងនៅពេលដែលពួកលោក
រកឃើញព្រះយេស៊ូ។ ទ្រង់បាន
មានបន្ទូលកុហកថា “យើង
ចង់ថ្វាយបង្គំទ្រង់ដែរ” តាម
ពិតទៅ ស្ដេចហេរ៉ូតចង់
សម្លាប់ព្រះយេស៊ូ
ទៅវិញទេ។
16
ផ្កាយបាននាំពួកអ្នកប្រាជ្ញទៅ
ដល់ចំផ្ទះដែលម៉ារី និងយ៉ូសែប
រស់នៅជាមួយព្រះកុមារយេស៊ូ។
ពួកលោកក៏បានលុតជង្គង់ចុះ
ថ្វាយបង្គំទ្រង់ ព្រមទាំងបាន
ថ្វាយព្រះយេស៊ូនូវដង្វាយជា
មាស និងទឹកអប់
ជាច្រើនផងដែរ។
17
ព្រះជាម្ចាស់បានព្រមានដល់ពួក
អ្នកប្រាជ្ញអោយត្រលប់ទៅស្រុក
របស់គេវិញជាសម្ងាត់។ ស្ដេចហេ
រ៉ូតខឹងសម្បារខ្លាំងណាស់។ ហេតុ
តែចង់បំផ្លាញព្រះយេស៊ូ ស្ដេចដ៏
អាក្រក់នេះក៏បានបញ្ជាអោយសំ
លាប់គ្រប់ក្មេងប្រុសៗទាំង
អស់នៅ
បិតថ្លេ
ហែម។
18
ប៉ុន្ដែស្ដេចហេរ៉ូតមិន
អាចបង្កគ្រោះថ្នាក់ដល់
ព្រះបុត្រារបស់ព្រះបាន
ឡើយ! ដោយទទួលបាន
ការព្រមានជាមុននៅ
ក្នុងការពន្យល់សប្តិ
យ៉ូសែបបាននាំម៉ារី និង
ព្រះយេស៊ូគេចខ្លួនទៅអេ
ស៊ីបដោយសុវត្ថិភាព។
19
នៅពេលដែលស្ដេ
ចហេរ៉ូតសោយទិវង្គត់
យ៉ូសែបបាននាំម៉ារី
និងព្រះ
យេស៊ូត្រលប់ពីអេស៊ីបវិញ។
ពួកគេបានរស់នៅក្នុងភូមិតូចមួយ
ឈ្មោះណាស្សារ៉ែត នៅជិតសមុទ្រកាលីឡេ។
20

ព្រះរាជកំណើតនៃព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគុម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ១-២, លូកា ១-២

“ការបើកសម្តែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់ ដែលទ្រង់ហៅការទាំងនោះថាអំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់។

ព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម៉្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ពេលនេះព្រះអង្គអាចអភ័យទោសរាល់អំពើបាបរបស់យើងបានហើយ។

ប្រសិនបើអ្នកចង់បែរចេញពីអំពើបាបរបស់អ្នក អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ព្រះអង្គអើយ ទូលបង្គំជឿហើយថា ព្រះយេស៊ូបានសុគតជំនួសខ្ញុំ ហើយទ្រង់បានរស់ឡើងវិញពីសេចក្តីស្លាប់។ សូមទ្រង់ចូលមកក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីអោយទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយបន្ទាប់មកនឹងបានទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយរស់នៅសំរាប់ទ្រង់ ដូចជាបុត្ររបស់ទ្រង់។
អាម៉ែន។ យូហាន ៣៖១៦

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទូលទៅកាន់ព្រះជារៀងរាល់ថ្ងៃ!